នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ឯកសារបកប្រែ |
|---|
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 31-Mar-2015, 10:00 |
| CMS/CFO: Sann Rada |

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស |
| ភាគីដាក់ឯកសារ | ៖ | មេធាវីការពារក្តីរបស់លោក មាស មុត |
| ដាក់ជូន | ៖ | សហចៅក្រមស៊ើបអង្កេត |
| ភាសាដើម | ៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ | ៖ | ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣ |

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សម្ងាត់/Confidential

ចំណាត់ថ្នាក់ប្រភេទឯកសារ៖ ប្តូរទៅជាសាធារណៈ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ញត្តិរបស់ មាស មុត ប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) តទៅនេះ លោក មាស មុត សូមដាក់ញត្តិប្រឆាំងនឹងការអនុវត្តសហឧក្រិដ្ឋរួម ទម្រង់ទី ៣ នៅក្នុងសំណុំរឿងរបស់គាត់។ ញត្តិនេះត្រូវធ្វើឡើងជាចាំបាច់ ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចោទប្រកាន់ថា លោក មាស មុត ទទួលខុសត្រូវចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋតាមរយៈសហឧក្រិដ្ឋរួមទម្រង់ទី ៣ ផងដែរ។ សហឧក្រិដ្ឋរួមទម្រង់ទី ៣ ជាទម្រង់មួយនៃការទទួលខុសត្រូវ ដែលមិនត្រូវបានទទួលស្គាល់នៅឯ អ.វ.ត.ក ទេ។ សំណើនេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ ដែលចែងថា “ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន *ត្រូវតែ* បកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ...។ ក្នុងបរិបទនេះ ក) កិច្ចដំណើរការនីតិវិធីនៅក្នុង អ.វ.ត.ក ត្រូវតែមានយុត្តិធម៌ និង តម្លាភាព...”។ ក្រុមមេធាវីការពារក្តីស្នើសុំដាក់ញត្តិនេះជាភាសាអង់គ្លេសជាមុនសិន ហើយនឹងដាក់ឯកសារបកប្រែជាភាសាខ្មែរតាមក្រោយ ពីព្រោះអង្គភាពបកប្រែភាសាមិនអាចបកប្រែឲ្យបានទាន់ពេលវេលានោះទេ ដោយសារខ្លួនមានការបកប្រែជាអាទិភាពដទៃទៀត[1]។

## I. សាវតារ

១. នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨ ក្នុងសំណុំរឿង ០០២ ក្រុមមេធាវីការពារក្តី អៀង សារី បានដាក់សំណើសុំការពិចារណាទៅកាន់ ក.ស.ច.ស ប្រឆាំងនឹងការអនុវត្តរាល់ទម្រង់[2] នៃសហឧក្រិដ្ឋកម្មរួម[3]

[1] *សូមមើល* អ៊ីមែលពីអង្គភាពបកប្រែភាសា ផ្ញើជូនក្រុមមេធាវីការពារក្តី “កម្មវត្ថុ៖ សំណើសុំបកប្រែឯកសារ” ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣។

[2] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (“ICTY”) បានកំណត់ទម្រង់បីនៃសហឧក្រិដ្ឋកម្មរួម៖ ទម្រង់មូលដ្ឋាន (សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១) ចាត់ទុកថាទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល កាលណា “សហជនជាប់ចោទទាំងអស់ ប្រព្រឹត្តទៅតាមផែនការរួមមួយ មានចេតនាឧក្រិដ្ឋដូចគ្នា... ទោះបីជាសហចារីម្នាក់ៗបំពេញតួនាទីផ្សេងៗគ្នាក្នុងការប្រព្រឹត្តនេះក៏ដោយ”។ *ព្រះរាជអាជ្ញា តទល់នឹង* *Tadić*, IT-94-1-A, សាលក្រម ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩៦។ ទម្រង់លក្ខណៈជាប្រព័ន្ធ (សហឧក្រិដ្ឋរួមទម្រង់ទី ២) ចាត់ទុកថាទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល កាលណា “បទល្មើសត្រូវបានចោទប្រកាន់ ថាបានប្រព្រឹត្តដោយសមាជិកនៃកងយោធា ឬ រដ្ឋបាលដូចជាកងដែលគ្រប់គ្រងមណ្ឌលប្រមូលផ្តុំ មានន័យថា ប្រព្រឹត្តដោយមនុស្សមួយក្រុមតាមផែនការរួមមួយ”។ *ព្រះរាជអាជ្ញា តទល់នឹង Tadić*, IT-94-1-A, សាលក្រម ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២០២។ ទម្រង់លាតសន្ធឹង (សហឧក្រិដ្ឋរួមទម្រង់ទី ៣) ចាត់ទុកថាទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល នៅក្នុងស្ថានភាព “ពាក់ព័ន្ធនឹងគោលបំណងរួមមួយក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ កាលណាមានចារីម្នាក់ក្នុងចំណោមចារីទាំងអស់ប្រព្រឹត្តអំពើមួយដែលទោះបីជាស្ថិតនៅក្រៅផែនការរួម ក៏ដោយ ក៏ជាផលវិបាកធម្មជាតិ និង ត្រូវបានមើលឃើញជាមុននៃលទ្ធផលរបស់ផែនការរួមនោះ”។ *ព្រះរាជអាជ្ញា តទល់នឹង Vasiljević*, IT-98-32-A, សាលក្រម, ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០០៤ កថាខណ្ឌ ៩៩។

មេធាវីការពាក្តី អៀង សារី បានអះអាងថា សហឧក្រិដ្ឋកម្មរួមមិនអាចត្រូវបានអនុវត្ត ដោយមូលហេតុ ក) មិនមានចែងជាក់លាក់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ខ) មិនពាក់ព័ន្ធនឹងច្បាប់កម្ពុជា គ) មិនត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទទួលស្គាល់វាឥឡូវនេះក៏ដោយ ក៏មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-១៩៧៩ ឬ ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជានោះដែរ និង ឃ) មិនត្រូវបានទទួលស្គាល់ដោយអនុសញ្ញាអន្តរជាតិមួយដែលត្រូវបានអនុវត្តនៅឯ អ.វ.ត.ក។ ដូច្នេះ ការអនុវត្តសហឧក្រិដ្ឋរួម នៅឯ អ.វ.ត.ក នឹងរំលោភបំពានលើគោលការណ៍ គ្មានច្បាប់ចែងគ្មានបទល្មើស (*nullum crimen sine lege*)។

២. នៅថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០៨ ក.ស.ចៅ.ស បានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ ដោយមិនបានអនុវត្តសហឧក្រិដ្ឋរួម ជាទម្រង់មួយនៃការទទួលខុសត្រូវឡើយ[4]។

៣. នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ ក.ស.ព ប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ ដោយអះអាងថា សហឧក្រិដ្ឋកម្មរួម គួរតែត្រូវបានអនុវត្ត[5]។

៤. នៅថ្ងៃទី ២៣ និង ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ប្រឈមមុខនឹងបញ្ហាសំខាន់នៃការដោះស្រាយបញ្ហាជាលើកដំបូង ដែលប៉ះពាល់ដល់ជនត្រូវចោទទាំងអស់នៅ អ.វ.ត.ក អង្គបុរេជំនុំជម្រះបានស្វះស្វែងរកជំនួយពីអ្នកខាងក្រៅ តាមរយៈការស្នើសុំសារណារបស់មិត្តតុលាការពីលោកសាស្ត្រាចារ្យ Antonio Cassese នៃមជ្ឈមណ្ឌលសម្រាប់សិទ្ធិមនុស្ស និង ពហុភាពគតិយុត្តិនៃសាកលវិទ្យាល័យ McGill និង សាស្ត្រាចារ្យបណ្ឌិត Kai Ambos នៃសាកលវិទ្យាល័យ Georg-August Universität Göttingen ។ មិត្តរបស់តុលាការត្រូវបានសុំឲ្យផ្តល់យោបល់លើ ក) ការបង្កើតទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម និង ការវិវត្តនៃនិយមន័យរបស់ទម្រង់នៃការទទួលខុសត្រូវនេះ ដោយយោងជាពិសេសទៅលើរយៈកាលនៃឆ្នាំ

---

[3] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ចៅ.ស, ញត្តិរបស់ អៀង សារី ប្រឆាំងនឹងការអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ ដែលហៅថា សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨។

[4] *រឿងក្តី កាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ចៅ.ស, ដីកាដំណោះស្រាយ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99។

[5] *រឿងក្តី កាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ចៅ.ស (អបជ), បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ D99/3/3, ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៤៣-៧២។

១៩៧៥-១៩៧៩ និង ខ) ថាតើសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់មួយនៃការទទួលខុសត្រូវ អាចត្រូវបានអនុវត្តនៅចំពោះមុខ អ.វ.ត.ក ដែរឬទេ ដោយគិតពីការណ៍ដែលថា បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទាំងនោះ ត្រូវបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩[6]។

៥. នៅថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចរបស់ខ្លួន លើបណ្ដឹងឧទ្ធរណ៍របស់ ក.ស.ព ជំទាស់នឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១។ អង្គបុរេជំនុំជម្រះ បដិសេធមិនសម្រេចលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង ០០១ ដោយរកឃើញថាជនជាប់ចោទមិនបានទទួលដំណឹងគ្រប់គ្រាន់ថាសហឧក្រិដ្ឋកម្មរួមនេះអាចនឹងត្រូវបានអនុវត្ត[7]។

៦. នៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩ ក.ស.ព បានដាក់សំណើមួយទៅកាន់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០១ ដើម្បីប្រកាសថា ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅ អ.វ.ត.ក និង ប្រកាសអនុវត្តសហឧក្រិដ្ឋកម្មរួមប្រឆាំងនឹង ឌុច[8]។

៧. នៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ នៅក្នុងសវនាការក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងគូសបញ្ជាក់ថា៖

> អង្គជំនុំជម្រះបានកត់សម្គាល់សេចក្ដីសន្និដ្ឋាន ដែលដាក់ដោយសហព្រះរាជអាជ្ញានៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩ ដែលស្នើឲ្យអង្គជំនុំជម្រះបញ្ជាក់ថា ទ្រឹស្ដីច្បាប់នៃសហឧក្រិដ្ឋកម្មរួមទាំងបីទម្រង់អាចអនុវត្តបាននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ និង អនុវត្តទ្រឹស្ដីនេះនៅក្នុងសាលក្រមរបស់ខ្លួនពាក់ព័ន្ធនឹងការប្រព្រឹត្តិបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ព្រមទាំងការទទួលខុសត្រូវរបស់គាត់ក្នុងនាមជាអ្នក

---

[6] *រឿងក្ដី កាំង ហ្កេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២), ការអញ្ជើញមិត្តតុលាការ, ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D/99/3/12។ *រឿងក្ដី កាំង ហ្កេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២), ការអញ្ជើញមិត្តតុលាការ, ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨, ឯកសារ D/99/3/13។ *រឿងក្ដី កាំង ហ្កេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២), ការអញ្ជើញមិត្តតុលាការ, ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D/99/3/14។

[7] *រឿងក្ដី កាំង ហ្កេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០២), សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយចោទប្រកាន់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ១៤១-៤២។

[8] *រឿងក្ដី កាំង ហ្កេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ E73។

ចូលរួមម្នាក់នៅក្នុងសហឧក្រិដ្ឋកម្មរួមមួយ។ អង្គជំនុំជម្រះសាលាដំបូងរំឭកឡើងវិញថា សហព្រះរាជអាជ្ញាបានគូសបញ្ជាក់អំពីបំណងក្នុងការពឹងផ្អែកលើទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួមនេះ នៅក្នុងសវនាការបឋម។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា បញ្ហាទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទ រួមទាំងជាអ្នកចូលរួមម្នាក់ក្នុងសហឧក្រិដ្ឋរួមមួយ កំពុងតែស្ថិតនៅចំពោះមុខអង្គជំនុំជម្រះ ហើយនិងអញ្ជើញភាគីឲ្យដាក់សំណើសុំការពិចារណា ពាក់ព័ន្ធនឹងការដាក់ឯកសាររបស់សហព្រះរាជអាជ្ញា អនុលោមតាមសេចក្តីណែនាំអនុវត្ត និង ជាពិសេស ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងនៃភាសាដែលត្រូវការ។ ចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះនឹងពិចារណាលើការចេញសេចក្តីសម្រេចរបស់ខ្លួនលើបញ្ហានេះ ស្របពេលគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តី[9]។

៨. នៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០០៩ ក.ស.ព បានផ្តួចផ្តើមឲ្យស៊ើបអង្កេតតាមផ្លូវតុលាការលើលោក មាស មុត ក្នុងសំណុំរឿង ០០៣ ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់ ក.ស.ព ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹងកងទ័ពបដិវត្តន៍កម្ពុជា[10]។ កថាខណ្ឌ ៩៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចែងថា៖

> នៅពេល ស៊ូ ម៉េត និង មាស មុត បានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ពួកគេបានប្រព្រឹត្តដោយបុគ្គលផ្ទាល់ខ្លួន ឬតាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋរួមមួយ ជាមួយសហចារីដទៃទៀត ដែលមានកំណត់អត្តសញ្ញាណនៅក្នុងកថាខណ្ឌ ៣៣ ដល់ ៤១ នៃដីកានេះ។ បទឧក្រិដ្ឋទាំងនេះគឺជាកម្មវត្ថុនៃសហឧក្រិដ្ឋរួម *ឬ ផលវិបាកតាមសភាពធម្មជាតិ និង ដែលអាចប្រមើលទុកជាមុននៃសហឧក្រិដ្ឋរួម*។ សមាជិកដទៃទៀតនៃសហឧក្រិដ្ឋរួម បានប្រព្រឹត្តដោយផ្អែកលើមូលដ្ឋាននៃគោលបំណងដូចគ្នា និង ចេតនារួមគ្នា[11]។

៩. នៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៩ ក.ស.ច.ស បានចេញដីកាមួយក្នុងសំណុំរឿង ០០២ រកឃើញថា សហឧក្រិដ្ឋរួមអាចត្រូវបានអនុវត្តគ្រប់ទម្រង់ទាំងអស់ក្នុងចំណោមទម្រង់ទាំងបី[12]។ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា តាមច្បាប់ជាតិ[13] សហឧក្រិដ្ឋកម្មរួម *មិនមែន* ជាទម្រង់មួយនៃការទទួល

---

[9] *រឿងក្តី កាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ឯកសារ E1/39.1 ទំព័រ ៨-៩។

[10] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងកងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D56/3.1 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ")។

[11] មានគូសបញ្ជាក់បន្ថែម។

[12] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារ D97/13។

[13] *ដូចខាងលើ កថាខណ្ឌ ២២*។

ខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ និង បានរកឃើញថា រាល់ទម្រង់នៃសហឧក្រិដ្ឋកម្មរួម ដូចដែលបាន បញ្ជាក់យ៉ាងច្បាស់ដោយតុលាការ ICTY ក្នុងរឿងក្តី *Tadić* និង សេចក្តីសម្រេចដែលពាក់ព័ន្ធរបស់ខ្លួន អាចអនុវត្តបាននៅ អ.វ.ត.ក វាជាទម្រង់មួយនៃ "ការប្រព្រឹត្តិ" ដូចដែលមានចែងក្នុងច្បាប់ទំនៀម ទម្លាប់អន្តរជាតិ[14]។ ដីកាសម្រេចនោះត្រូវបានប្តឹងឧទ្ធរណ៍[15]។ ជាពិសេសក្រុមមេធាវីការពារក្តី អៀង សារី បានជំទាស់យ៉ាងច្រើនទៅនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវនៅ អ.វ.ត.ក[16]។

១០. នៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស. ដែលសម្រេចថា សហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅ អ.វ.ត.ក.។ អង្គបុរេជំនុំជម្រះបានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង មិនអាចអនុវត្តបាននៅ អ.វ.ត.ក ឡើយ[17]។ អង្គបុរេជំនុំជម្រះបានពិនិត្យឯកសារច្បាប់ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY យកមកធ្វើជាសម្អាងក្នុងរឿងក្តី *Tadić* ពាក់ព័ន្ធនឹងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣។ អង្គបុរេជំនុំជម្រះបានរកឃើញថា ធម្មនុញ្ញទីក្រុងឡុងដ៏ និង ច្បាប់ក្រុមប្រឹក្សាគ្រប់គ្រងលេខ ១០ មិនបានផ្តល់ការគាំទ្រដល់អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នេះទេ។ អង្គបុរេជំនុំជម្រះបានរកឃើញបន្ថែមទៀតថា សេចក្តីព្រាងនៃលក្ខន្តិកៈរបស់តុលាការ

---

[14] *ដូចខាងលើ កថាខណ្ឌ ១៣*។

[15] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៧), បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធចំនួន ២, ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១០ ឯកសារ D97/14/5។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៧), [ដើមបណ្តឹងរដ្ឋប្បវេណី] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១០ ឯកសារ D97/17/1។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៧), បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០១០ ឯកសារ D97/15/1។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៧), [ខៀវ សំផន] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១០ ឯកសារ D97/16/1។

[16] *សូមមើល* ឧបសម្ព័ន្ធ ស្តីពីបញ្ជីនៃការដាក់ឯកសាររបស់មេធាវីការពារក្តីរបស់ អៀង សារី ពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម។

[17] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីសហឧក្រិដ្ឋកម្មរួមរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០។

ព្រហ្មទណ្ឌអន្តរជាតិ និង អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាបការដាក់គ្រាប់បែករបស់ពួកភេរវជន មិនគាំទ្រដល់អត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥-១៩៧៩ នេះទេ ពីព្រោះថាលិខិតុបករណ៍ទាំងនេះកើតមាននៅក្រោយអំឡុងពេលនោះ[18]។ អង្គបុរេជំនុំជម្រះបានរកឃើញថា ទោះបីជាអង្គហេតុពីរនៅក្រោយសង្គ្រាមលោកលើកទី ២ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* (*Essen Lynching* និង *Borkum Island*) យកមកសម្អាង អាចពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋរួមទម្រង់ទី ៣ យ៉ាងណាក្តី ក៏ភាពខ្វះសម្អាងហេតុនៅក្នុងសេចក្តីសម្រេចនានានៅក្នុងរឿងក្តីទាំងនោះ បង្កើតឲ្យភាពមិនច្បាស់លាស់ក្នុងការអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះ[19]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* បានពឹងផ្អែកលើរឿងក្តីខ្លះរបស់ អ៊ីតាលី ប៉ុន្តែមិនបានរកឃើញថា គេអាចយកសេចក្តីសម្រេចជាតិ មកធ្វើជាយុត្តិសាស្ត្រសម្រាប់អនុវត្តទម្រង់នៃការទទួលខុសត្រូវបែបអន្តរជាតិនេះទេ។ សេចក្តីសម្រេចដ៏គួរកត់សម្គាល់នេះ[20] ទទួលបានការកោតសរសើរចំពោះការវិភាគស៊ីជម្រៅ ពីសំណាក់ចៅក្រម Wolfgang Schomburg ដែលជាអតីតចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY/ICTR ដែលបានយល់ឃើញថាសេចក្តីសម្រេចនេះ "ជាសេចក្តីសម្រេចគួរឲ្យកោតសរសើរចំពោះការវិភាគដែលហ្មត់ចត់ទៅលើសេចក្តីសម្រេចមួយចំនួនពាក់ព័ន្ធនឹងករណីក្រោយសង្គ្រាមលោកលើកទី ២" និង ជាលទ្ធផលដែល "គួរឲ្យសាទរយ៉ាងខ្លាំង បន្ទាប់ពីមានការភ័ន្តច្រឡំអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ"[21]។ សាស្ត្រាចារ្យ Jens David Ohlin នៃសាកលវិទ្យាល័យច្បាប់ Cornell បានកត់សម្គាល់ឃើញថា សេចក្តីសម្រេចនេះត្រូវបាន "តាក់តែងឡើងបានយ៉ាងល្អ និង វិភាគវែកញែកបានយ៉ាងល្អិតល្អន់"[22]។

---

[18] *ដូចខាងលើ កថាខណ្ឌ ៧៨។*

[19] *ដូចខាងលើ កថាខណ្ឌ ៧៩-៨១។*

[20] Kevin Jon Heller, *អ.វ.ត.ក ចេញសេចក្តីសម្រេចគួរឲ្យកត់សម្គាល់មួយស្តីពីសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣*, ទស្សនៈច្បាប់, ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១០។

[21] ចៅក្រម Wolfgang Schomburg, *យុត្តិសាស្ត្រស្តីពីសហឧក្រិដ្ឋកម្មរួម– Revisiting a Never Ending Story*, ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១០ ទំព័រ ២៨ អាចរកអានបាននៅ http://www.cambodiatribunal.org/sites/default/files/resources/ctm_blog_6_1_2010.pdf.

[22] Jens David Ohlin, *ចេតនារួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិ*, 11 CHI. J. INT'L L. 693, 748 (2011): "នៅក្នុងគំនិតដែលឆ្លងតាមការវិភាគច្បាស់លាស់ និង ស៊ីជម្រៅ ដែលជាសញ្ញាដ៏ល្អនៃសាលាក្តីក្មេងខ្ចីនេះ អង្គបុរេជំនុំជម្រះបានពិនិត្យរាល់យុត្តិសាស្ត្រក្នុងប្រវត្តិសាស្ត្រនៃសម័យក្រោយសង្គ្រាមលោកលើកទី ២ និង ពិនិត្យស៊ីជម្រៅលើសពីករណីនានាដែលត្រូវបានដកស្រង់ដោយតុលាការ ICTY ក្នុងរឿងក្តី *Tadic*"។

១១. នៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមក្នុងរឿងក្តី ០០១[23]។ នៅក្នុងសាលក្រមនេះ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា អង្គជំនុំជម្រះមិនជាប់កាតព្វកិច្ចត្រូវអនុវត្តតាមការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះឡើយ[24]។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង បានអនុញ្ញាតឲ្យអង្គជំនុំជម្រះផ្លាស់ប្តូរការកំណត់លក្ខណៈបទល្មើសតាមផ្លូវច្បាប់ និង ទម្រង់នានានៃការទទួលខុសត្រូវដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឲ្យតែការផ្លាស់ប្តូរនេះមិនប្រាសចាកពីអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ[25]។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់លក្ខណៈឡើងវិញនូវទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីអនុវត្តសហឧក្រិដ្ឋកម្មរួមជាទម្រង់មួយនៃការទទួលខុសត្រូវ[26]។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងរកឃើញថាការទទួលខុសត្រូវតាមទម្រង់នៃសហឧក្រិដ្ឋកម្មរួម អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[27] និងថា ការកំណត់លក្ខណៈឡើងវិញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីបញ្ចូលសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវ នឹងមិនរំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ[28]។ ដោយសារតែ ក.ស.ព បានគូសបញ្ជាក់ថា ខ្លួននឹងពឹងផ្អែកជាចម្បងទៅលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ និង ទី ២ និង ពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ តែក្នុងករណីជាជម្រើសផ្សេងទៀតនៃទម្រង់នៃការទទួលខុសត្រូវប៉ុណ្ណោះ អង្គជំនុំជម្រះសាលាដំបូងមិនបានប្រកាសអំពីឋានៈជាទំនៀមទម្លាប់នៃសហឧក្រិដ្ឋរួមទម្រង់ទី ៣ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[29]។

១២. នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២[30]។ សហចៅក្រមស៊ើបអង្កេត បានដកស្រង់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុង

---

[23] *រឿងក្តី កាំង ហ្គេកអ៊ាវ*, ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ឯកសារ E188។

[24] *ដូចខាងលើ* កថាខណ្ឌ ៤៩២។

[25] *ដូចខាងលើ* កថាខណ្ឌ ៤៩៣, ៤៩៦។

[26] *ដូចខាងលើ* កថាខណ្ឌ ៤៩៦។

[27] *ដូចខាងលើ* កថាខណ្ឌ ៥១១-១២។

[28] *ដូចខាងលើ* កថាខណ្ឌ ៥០២-០៣។

[29] *ដូចខាងលើ* កថាខណ្ឌ ៥១៣។

[30] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427។

សំណុំរឿង ០០២ ដោយបានកត់សម្គាល់ថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ១ និង ទី ២ អាចអនុវត្តបាន នៅចំពោះមុខ អ.វ.ត.ក[31] និង បានអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ១[32]។

១៣. នៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១១ ក.ស.ព ជៀសជាងប្តឹងជំទាស់ទៅនឹងដីកាដំណោះស្រាយក្នុង សំណុំរឿង ០០២ បែរជាដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យកំណត់លក្ខណៈឡើងវិញនូវ អង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ ដើម្បីដាក់បញ្ចូលទម្រង់នៃការទទួលខុសត្រូវនៃសហ ឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទៅវិញ[33]។ ក្រុមមេធាវីការពារក្តីនីមួយៗបានឆ្លើយតប ដោយអះអាងថា សំណើនេះគួរតែត្រូវបានសម្រេចថាមិនអាចទទួលយកបាន ឬ បដិសេធចោល[34]។

---

[31] *ដូចខាងលើ* កថាខណ្ឌ ១៣១៨ កំណត់ចំណាំលេខ ៥២១៧។

[32] *ដូចខាងលើ* កថាខណ្ឌ ១៥៤១។

[33] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យ អង្គជំនុំជម្រះសាលាដំបូងចាត់ទុក សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាជម្រើសផ្សេងមួយនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E100។

[34] *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចម្លើយតបរបស់មេធាវីការពារក្តី [អៀង ធីរិទ្ធ] ទៅនឹងសំណើរបស់សហព្រះរាអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុក សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាជម្រើស ផ្សេងមួយនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ E100/1។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាអាជ្ញា សុំឲ្យ អង្គជំនុំជម្រះសាលាដំបូងចាត់ទុក សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាជម្រើសផ្សេងមួយនៃទម្រង់នៃការទទួលខុសត្រូវ និង សំណើ សុំឲ្យមានសវនាការផ្ទាល់មាត់មួយ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ E100/2។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចម្លើយតបរបស់ [ខៀវ សំផន] ទៅនឹងសំណើរបស់សហព្រះរាអាជ្ញាពាក់ព័ន្ធនឹង សហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ E100/3។ *រឿងក្តី នួន ជា និងអ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ចម្លើយតបរបស់ [នួន ជា] ទៅនឹងសំណើរបស់សហព្រះរាអាជ្ញា សុំឲ្យ អង្គជំនុំជម្រះសាលាដំបូងចាត់ទុក សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាជម្រើសផ្សេងមួយនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ E100/5។ មេធាវីការពារក្តី អៀង សារី បានអះអាងថា សំណើរបស់ ក.ស.ព គួរតែត្រូវ បានបដិសេធចោល ព្រោះវាជាការជំទាស់បឋមដែលមិនសមនឹងពេលវេលា ឬ ជាជម្រើសម្យ៉ាងទៀត សំណើនេះគួរតែត្រូវបាន បដិសេធចោល ដោយសារខ្វះអង្គសេចក្តី ដ្បិតគ្រប់អំណះអំណាងទាំងអស់របស់ ក.ស.ព សុទ្ធតែត្រូវបានលើកឡើងរួចមក ហើយនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ សំណើនេះមិនបានបង្ហាញអំពីកំហុសឆ្គងពិតប្រាកដណាមួយ នៅក្នុងសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះ ដែលថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនអាចអនុវត្តបាននៅ អ.វ.ត.ក ដែលនាំឲ្យអង្គជំនុំជម្រះសាលា ដំបូងសម្រេចផ្ទុយពីនេះនោះឡើយ។

១៤. នៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចលើសំណើរបស់ ក.ស.ព សម្រេចតម្កល់សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលថាសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនអាចអនុវត្តបាននៅ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានពិនិត្យឡើងវិញយ៉ាងល្អិតល្អន់ និង ត្រឹមត្រូវនូវលិខិតុបករណ៍គតិយុត្តិនៅមុនឆ្នាំ ១៩៧៥ និង យុត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី ២ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្ដី *Tadić* យកមកធ្វើជាសម្អាង។ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ខ្លួននឹងមិន "ចេញសេចក្ដីសម្រេចវែងនោះទេ ក្នុងកាលៈទេសៈដែលខ្លួនរកមិនឃើញនូវមូលហេតុរឹងមាំ ដើម្បីងាកចេញពីការវិភាគរបស់អង្គបុរេជំនុំជម្រះ និង ក្នុងករណីដែលខ្លួនយល់ស្របជាមួយនឹងលទ្ធផលរបស់អង្គបុរេជំនុំជម្រះ"[35]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើករណីនានានៅក្រោយសង្គ្រាមលោកលើកទី ២ ដែលត្រូវបានដកស្រង់នៅក្នុងសាលដីកាក្នុងរឿងក្ដី *Tadić* និង ករណីបន្ថែមចំនួនពីរទៀតនៅក្នុងសម័យសង្គ្រាមលោកលើកទី ២ ដែលត្រូវបានដកស្រង់នៅក្នុងសេចក្ដីសម្រេចរបស់សាលាក្ដីពិសេសសម្រាប់ប្រទេស លីបង់ ដែលពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម[36]។ ដោយសារតែមូលដ្ឋានច្បាប់សម្រាប់ការផ្ដន្ទាទោស មិនមានភាពច្បាស់លាស់នៅក្នុងករណីទាំងពីរនោះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ករណីទាំងនោះមិនអាចគាំទ្រឡើយនូវសេចក្ដីសន្និដ្ឋានមួយដែលថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ បានលេចឡើងជាគោលការណ៍មួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ ១៩៧៥-១៩៧៩[37]។ ទីបំផុត អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា តើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ស្ថិតនៅជាគោលការណ៍ទូទៅមួយនៃច្បាប់នៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ដែរឬទេ តាមរយៈការពិនិត្យមើលប្រព័ន្ធច្បាប់របស់រដ្ឋផ្សេងៗ។ អង្គជំនុំជម្រះសាលាដំបូង

---

[35] *រឿងក្ដី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 កថាខណ្ឌ ២៦។

[36] *ដូចខាងលើ* កថាខណ្ឌ ៣០-៣៤។ នៅក្នុងសេចក្ដីសម្រេចរបស់សាលាក្ដីពិសេសសម្រាប់ប្រទេស លីបង់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដែលនៅក្នុងនោះចៅក្រម Cassese ជាប្រធាន និង ចៅក្រមរបាយការណ៍ បានពិចារណាលើបញ្ហាជាច្រើនដែលដាក់ដោយអង្គបុរេជំនុំជម្រះ រួមទាំងបញ្ហាមួយដែលពាក់ព័ន្ធនឹងទម្រង់នានានៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ដែលត្រូវជំនុំជម្រះនៅចំពោះមុខសាលាក្ដីនោះផង។ សេចក្ដីសម្រេចភ្លាមៗលើច្បាប់ជាធរមាន៖ ភេរវកម្ម, ការសមគំនិត, មនុស្សឃាត, ការប្រព្រឹត្តបទឧក្រិដ្ឋ, ការចោទប្រកាន់ត្រួតគ្នា, STL-11-01/1, ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១ កំណត់សង្ខេបនៃរឿងក្ដី ទំព័រ ១។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានអះអាងជាថ្មីនូវយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី ២ ដែលដកស្រង់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្ដី *Tadić* និង បានយោងបន្ថែមនូវករណី *Ulrich និង Merkle* និង *Wuelfert* ដែលជាករណីដែលគាំទ្រសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ថាជាទម្រង់មួយនៃការទទួលខុសត្រូវ។ *ដូចខាងលើ* កថាខណ្ឌ ២៣៧ កំណត់សម្គាល់ ៣៥៥។

[37] *រឿងក្ដី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 កថាខណ្ឌ ៣៥។

បានរកឃើញថាមាន "ភាពខុសគ្នាយ៉ាងច្រើននៃវិធីសាស្ត្រក្នុងចំណោមយុត្តាធិការជាតិផ្សេងៗគ្នា" និង ហេតុដូច្នេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានបានថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ គឺជាគោលការណ៍ទូទៅនៃច្បាប់ឡើយ[38]។ ក.ស.ព មិនបានប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះទេ។

## II. ច្បាប់ និង ឧទ្ធរណ៍

### ក) សហចៅក្រមស៊ើបអង្កេតត្រូវតែអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង ដែលបានសម្រេចថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនអាចអនុវត្តបាននៅ អ.វ.ត.ក

១៥. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ ស្នើឲ្យសហចៅក្រមស៊ើបអង្កេតចាត់ទុកការ ទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ជាជម្រើសផ្សេងមួយនៃទម្រង់នៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[39]។ នៅពេលដែលរៀបចំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានសម្រេចនៅឡើយទេថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មិនអាចអនុវត្តបាននៅ អ.វ.ត.ក។ បន្ទាប់ពីអង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ក.ស.ព មិនបានស្នើសុំកែប្រែដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីឲ្យស្របទៅតាមច្បាប់ជាធរមាន និង អនុវត្តបាននៅ អ.វ.ត.ក ឡើយ។

១៦. សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេតអនុវត្តតាម។ សហចៅក្រមស៊ើបអង្កេតពុំមានអំណាចឆន្ទានុសិទ្ធិ ក្នុងការជ្រើសរើសអនុវត្ត ឬ មិនអនុវត្តយុត្តិសាស្ត្រដែលបានបង្កើតឡើងដោយអង្គជំនុំជម្រះ ដ្បិតខ្លួនជាស្ថាប័នក្រោមបង្គាប់។ អង្គបុរេជំនុំជម្រះត្រូវបានបង្កើតឡើងជាពិសេស ដើម្បីធ្វើជាស្ថាប័នជាន់ខ្ពស់មួយ មានអំណាចពិនិត្យឡើងវិញនូវសកម្មភាព និង សេចក្ដីសម្រេចរបស់ ក.ស.ច.ស[40]។ អង្គបុរេជំនុំជម្រះបានពិនិត្យឡើងវិញ និង សម្រេចច្រានចោលសេចក្ដីសម្រេចជាច្រើនរបស់ ក.ស.ច.ស។ ឧទាហរណ៍ អង្គបុរេជំនុំជម្រះបានសម្រេចច្រានចោលសេចក្ដីសម្រេចមួយដែលបដិសេធមិនអនុញ្ញាតឲ្យលោក អៀង សារី ជួបប្រពន្ធរបស់គាត់ និង សេចក្ដី

---

[38] *ដូចខាងលើ* កថាខណ្ឌ ៣៧។

[39] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៩៧។

[40] *សូមមើល* វិធាន ៧៣។

សម្រេចមួយដែលបដិសេធមិនអនុញ្ញាតឲ្យមេធាវីការពារក្តីរបស់ អៀង សារី ថតវីដេអូនៅក្នុងកិច្ចប្រជុំរបស់ពួកគេជាមួយលោក អៀង សារី[41]។ ដោយទទួលស្គាល់ដោយស្ងៀមស្ងាត់ថា ខ្លួនត្រូវអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះក្នុងករណីដទៃទៀត ក្នុងពេលកន្លងមក ក.ស.ច.ស បានដកស្រង់ និង ពឹងផ្អែកលើយុត្តិសាស្ត្រនេះ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងនូវយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ ស្តីពីកាតព្វកិច្ចក្នុងផ្តល់សេចក្តីសម្រេចដែលមានសម្អាងហេតុ ដោយរកឃើញថាសេចក្តីសម្រេចមួយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Kasper-Ansermet គួរតែត្រូវបានពិចារណាឡើងវិញ ដោយសារសេចក្តីសម្រេចនោះពុំមានសម្អាងហេតុ[42]។

១៧. បើតាមលោកចៅក្រម Downing និង លោកចៅក្រម Chung នៃអង្គបុរេជំនុំជម្រះ៖

ពាក់ព័ន្ធនឹងលក្ខណៈត្រូវអនុវត្តតាមនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចំពោះសហចៅក្រមស៊ើបអង្កេត យើងយល់ថា គោលការណ៍សុចរិតភាពផ្លូវច្បាប់ និង សមភាពចំពោះមុខច្បាប់ ដែលមានចែងក្នុងវិធានផ្ទៃក្នុង និង ជាផ្នែកមួយនៃបទដ្ឋានអន្តរជាតិនោះ តម្រូវឲ្យសហចៅក្រមស៊ើបអង្កេតអនុវត្តតាមជាគោលការណ៍នូវ *ភាពសមហេតុផល* (*ration decidendi*) នៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលជាគោលការណ៍ច្បាប់ដែលសេចក្តីសម្រេចមួយត្រូវយកមកសម្អាង និង ដែលត្រូវអនុវត្តនៅក្នុងករណីស្រដៀងគ្នា ឬ មានខ្លឹមសារស្រដៀងគ្នា។ លក្ខណៈត្រូវអនុវត្តតាមនេះ ក៏ត្រូវបានគាំទ្រផងដែរ ដោយឋានានុក្រមនៃអំណាចតុលាការដែលអង្គបុរេជំនុំជម្រះមានទៅលើសហចៅក្រមស៊ើបអង្កេត ក្រោមប្រព័ន្ធច្បាប់ អ.វ.ត.ក និង ជាប្រយោជន៍នៃការគ្រប់គ្រងចំណាយផ្នែកតុលាការ និង ប្រសិទ្ធិភាពនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយសារថា សេចក្តីសម្រេចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលជាគោលការណ៍ ត្រូវអនុវត្តតាមសេចក្តីសម្រេចពីមុនរបស់ខ្លួនអនុលោមតាមបទដ្ឋានដែលត្រូវបានរៀបរាប់ខាងលើ ហើយអាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹង

---

[41] *សូមមើល រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ០៥), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងគ្នារវាងជនត្រូវចោទនិងប្រពន្ធរបស់គាត់ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៨ ឯកសារ A104/II/7។ *រឿងក្តី នួន ជា និង អ្នកដទៃទៀត*, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៦៤), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំការអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនូវការជួបប្រជុំជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12។

[42] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី [redacted] សុំចូលពិនិត្យមើលសំណុំរឿង និង ចូលរួមក្នុងការស៊ើបអង្កេត ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៣ ឯកសារ D121/4, កំណត់សម្គាល់ ៦៦។

បដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានដាកចេញពីយុត្តិសាស្ត្រពីមុនរបស់ខ្លួន[43]។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ មានលក្ខណៈគួរឱ្យជឿទុកចិត្ត និង មានអំណាចឱ្យអនុវត្តតាម។

១៨. បន្ថែមលើអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងក៏បំពេញមុខងារផងដែរ ជាស្ថាប័នខទ្ធរណ៍ដោយប្រយោលមួយសម្រាប់ ក.ស.ច.ស ដោយសារតែប្រព័ន្ធនីតិវិធីដែលមានជាធរមាននៅ អ.វ.ត.ក ដែលអនុញ្ញាតឱ្យលើកបញ្ហានៅដំណាក់កាលមុនជំនុំជម្រះ យកមកដោះស្រាយជាថ្មីនៅពេលជំនុំជម្រះ[44]។ ដើម្បីរក្សាឱ្យបាននូវយុត្តិសាស្ត្រពីមុនរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងនឹងមិនអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ប្រឆាំងនឹងលោក មាស មុត នៅពេលជំនុំជម្រះនោះទេ។

១៩. ដើម្បីប្រយោជន៍យុត្តិធម៌ ការគ្រប់គ្រងចំណាយក្នុងតុលាការ និង ភាពឆាប់រហ័ស សហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើតាម និង អនុវត្តដោយស្មោះត្រង់នូវយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូង ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មទម្រង់ទី ៣។ ការបញ្ចូលណាមួយនូវការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ នឹងនាំឱ្យមានការរំលោភបំពានទៅលើដំណើរការរបស់តុលាការ។ ចៅក្រមមានកាតព្វកិច្ចមួយ

---

[43] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/3/4/2 កថាខណ្ឌ ១៧។

[44] ទីប្រឹក្សាច្បាប់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា លោក John Ciorciari និង លោកស្រី Anne Heindel បានពន្យល់ថា៖ "សំណួរអាចត្រូវបានចោទសួរយ៉ាងហោចណាស់ចំនួនបួនដង មុននឹងត្រូវបានដោះស្រាយ គឺនៅមុខសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល។ ឧទាហរណ៍ បញ្ហានៃការលើកលែងទោស និង ការអនុគ្រោះទោសលោក អៀង សារី នៅឆ្នាំ ១៩៩៦ ត្រូវបានដោះស្រាយដោយសហចៅក្រមស៊ើបអង្កេតចំនួនពីរដង ត្រូវបានពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះចំនួនពីរដង តាមរយៈបណ្តឹងឧទ្ធរណ៍ បន្ទាប់មកត្រូវបានពិនិត្យជាថ្មីម្តងទៀតដោយអង្គជំនុំជម្រះ មុននឹងត្រូវបានប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល មុនពេលលោក អៀង សារី ទទួលមរណៈភាព"។ លោក John D. Ciorciari និង លោកស្រី Anne Heindel, *ការធ្វើពិសោធន៍ក្នុងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ៖ សាលាក្តីខ្មែរក្រហម*, MICH. J. INT'L L. (ចេញផ្សាយឆាប់ៗ)។ *សូមមើលផងដែរ លោក* Michael Karnavas និង លោក អាង ឧត្តម, *ការការពារក្តីលោក អៀង សារី ដោយយកចិត្តទុកដាក់ មិនមែនជាយុទ្ធវិធីមួយពន្យារពេលឡើយ*, សារព័ត៌មាន ខេមបូឌា ដេលី ចេញផ្សាយថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០១១។ លោក Andrew Cayley, *ក្រុមមេធាវីការពារក្តី អៀង សារី មិនចាំបាច់សុំទោសចំពោះការបំពេញការងាររបស់ខ្លួននោះទេ*, សារព័ត៌មាន ខេមបូឌា ដេលី ចេញផ្សាយថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១១។

គឺអនុវត្តយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះជាន់ខ្ពស់[45]។ ដូចដែលបានពន្យល់ដោយចៅក្រម Hunt នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ពាក់ព័ន្ធនឹងការមិនបានអនុវត្តតាមសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ថា៖

> អង្គជំនុំជម្រះសាលាដំបូង បដិសេធមិនអនុវត្តតាមសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (ដែលខ្លួនត្រូវមានកាតព្វកិច្ចអនុវត្តតាម) ដោយសារតែខ្លួនគិតថាសេចក្តីសម្រេចនោះមិនត្រឹមត្រូវ... អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ និង ខ្លួនបានប្រព្រឹត្តខុសនឹងច្បាប់ ដោយបដិសេធមិនព្រមអនុវត្តតាមសេចក្តីសម្រេចនោះ។ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិបញ្ជាក់អំពីហេតុផលនៃការមិនយល់ស្របនឹងសេចក្តីសម្រេចបែបនោះរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ (គឺដូចគ្នាទៅនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើនៅទីនេះ) ហើយការមិនយល់ស្របដែលមានសម្អាងហេតុនេះ ក្នុងករណីសមស្របអាចនាំឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនរបស់ខ្លួន ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង នៅក្នុងខណៈនេះ ត្រូវទទួលយកដោយស្មោះត្រង់នូវសេចក្តីសម្រេចដែលខ្លួនជាប់កាតព្វកិច្ចត្រូវអនុវត្តតាម[46]។

---

[45] នេះគឺអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន ក្នុងការ "គោរព និង អនុវត្តតាមច្បាប់ និង [] ប្រព្រឹត្តគ្រប់ពេលវេលាក្នុងឥរិយាបថដែលជួយលើកកម្ពស់ជំនឿចិត្តរបស់សាធារណជនមកលើសុចរិតភាព និងអនាគតិរបស់តុលាការ"។ ក្រមសីលធម៌វិជ្ជាជីវៈតុលាការរបស់រដ្ឋកាលីហ្វ័រញ៉ា គោលការណ៍ចំណុច ២(ក), *អាចរកបាននៅ* www.courts.ca.gov/documents/ ca_code_judicial_ethics.pdf. ប្រសិនបើចៅក្រមមួយរូប មិនអើពើនឹងសមត្ថកិច្ចរបស់អង្គជំនុំជម្រះជាន់ខ្ពស់ដែលបង្កើតឡើងដោយច្បាប់ គឺមិនស្របទៅនឹងកាតព្វកិច្ចយកចិត្តទុកដាក់ខ្ពស់របស់ខ្លួនឡើយ។ *សូមមើល* ក្រមសីលធម៌តុលាការនៃ អ.វ.ត.ក មាត្រា ៥, ក្រមសីលធម៌វិជ្ជាជីវៈចៅក្រមកម្ពុជា ជំពូក ៦។ *សូមមើលផងដែរ* គោលការណ៍ចំណុច ២ នៃក្រមសីលធម៌គម្រូនៃវិជ្ជាជីវៈតុលាការនៃគណៈមេធាវីអាមេរិក៖ "ចៅក្រមត្រូវបំពេញករណីយកិច្ចនៃមុខងារតុលាការ ដោយឥតលម្អៀង យ៉ាងមានសមត្ថភាព និង ដោយយកចិត្តទុកដាក់ខ្ពស់"។

[46] *ព្រះរាជអាជ្ញា តទល់នឹង Blagojević និង Jokić*, IT-02-60-PT, សេចក្តីសម្រេចស្តីពីការដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ឬ Vidoje Blagojević និង Dragan Obrenović, យោបល់ដាច់ដោយឡែករបស់ចៅក្រោម David Hunt ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០២ កថាខណ្ឌ ៣, ៥។ *សូមមើលផងដែរ ព្រះរាជអាជ្ញា ទល់នឹង Aleksovski*, IT-95-14/1-A, សាលដីកាចុះថ្ងៃទី ២៤ ខែមិនា ឆ្នាំ ២០០០ កថាខណ្ឌ ១១៣៖ "អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ពិចារណាឃើញថា ការបកស្រាយមួយដ៏ត្រឹមត្រូវតាមខ្លឹមសាររបស់លក្ខន្តិកៈ ទាមទារឱ្យមានសម្អាងហេតុនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដែលចងអង្គជំនុំជម្រះសាលាដំបូងឱ្យអនុវត្តតាម ដោយសារមូលហេតុដូចតទៅ៖ (១) លក្ខន្តិកៈបង្កើតបានជារចនាសម្ព័ន្ធតាមឋានានុក្រមមួយ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ត្រូវមានមុខងារដាច់ខាតក្នុងការដោះស្រាយបញ្ហាអង្គច្បាប់ និង អង្គហេតុមួយចំនួន ដែលកើតចេញពីសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង។ អនុលោមតាមមាត្រា ២៥ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ជំនុំជម្រះបណ្តឹងសាទុក្ខដែលឈរលើមូលដ្ឋានកំហុសឆ្គងអង្គច្បាប់ ដែលនាំឱ្យមោឃភាពសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឬ ដែលឈរលើមូលដ្ឋានកំហុសឆ្គងអង្គហេតុ ដែលបណ្តាលឱ្យមានការខុសឆ្គោយក្នុងការជម្រះក្តី ហើយសេចក្តីសម្រេចរបស់ខ្លួន ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា (២) អាណត្តិជាមូលដ្ឋានរបស់សាលាក្តីក្នុងការជំនុំជម្រះជនដែលទទួលខុសត្រូវចំពោះការរំលោភ

២០. មិនត្រឹមតែសហចៅក្រមស៊ើបអង្កេតបានរំលោភកាតព្វកិច្ចតុលាការរបស់ខ្លួន ក្នុងការអនុវត្តតាមយុត្តិសាស្ត្រដែលបានបង្កើតរួចហើយប៉ុណ្ណោះទេ អង្គបុរេជំនុំជម្រះក៏ត្រូវតែបដិសេធយ៉ាងប្រាកដនូវសេចក្តីសម្រេចណាមួយដែលដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ទៅក្នុងដីកាដំណោះស្រាយ ហើយការទទួលខុសត្រូវបែបនេះ នឹងមិនត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកទៅពិចារណានៅពេលជំនុំជម្រះឡើយ។ សហចៅក្រមស៊ើបអង្កេត មិនអាចចេះតែចោទប្រកាន់លោក មាស មុត ថាបានប្រព្រឹត្តបទឧក្រិដ្ឋណាមួយដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ បានឡើយ។

### ខ) ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នឹងរំលោភសិទ្ធិទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នារបស់លោក មាស មុត

២១. លោក មាស មុត មានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នា នៅចំពោះមុខច្បាប់។ សិទ្ធិនេះត្រូវបានធានាជូនគាត់ ដោយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងមួយផ្នែកថា

---

បំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ មិនអាចទទួលបានជោគជ័យឡើយ ប្រសិនបើជនជាប់ចោទ និង ព្រះរាអាជ្ញាពុំមានការធានាច្បាស់លាស់អំពីភាពប្រាកដប្រជា និង ភាពអាចប្រមើលទុកមុននូវការអនុវត្តច្បាប់ជាធរមាន និង (៣) សិទ្ធិប្តឹងឧទ្ធរណ៍ដូចដែលអង្គជំនុំជម្រះបានគូសបញ្ជាក់ពីមុន គឺជាធាតុផ្សំមួយនៃលក្ខខណ្ឌតម្រូវឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលសិទ្ធិនេះគឺជាវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ដែលធានាឲ្យមានសិទ្ធិដល់ជនជាប់ចោទក្នុងការទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នាដូចជនជាប់ចោទដទៃទៀត។ សិទ្ធិនេះនឹងមិនអាចអនុវត្តបានទេ ប្រសិនបើអង្គជំនុំជម្រះនីមួយៗមានសេរីភាពក្នុងការបដិសេធចោលសេចក្តីសម្រេចលើអង្គច្បាប់ដែលចេញដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និង ប្រសិនបើអង្គជំនុំជម្រះនីមួយៗសម្រេចលើអង្គច្បាប់ទៅតាមតែអ្វីដែលខ្លួនយល់ថាសមស្រប។ ក្នុងប្រព័ន្ធបែបនេះ វាអាចបង្កើតឲ្យមានសេចក្តីសម្រេចបួនចេញពីសាលាក្តីលើបញ្ហាអង្គច្បាប់តែមួយ សេចក្តីសម្រេចមួយចេញពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ និង សេចក្តីសម្រេចចំនួនបីចេញពីអង្គជំនុំជម្រះទាំងបី ដែលមើលទៅហាក់បីដូចជាក្រុមប្រឹក្សាសន្តិសុខមិនមែនបង្កើតសាលាក្តីតែមួយទេ ប៉ុន្តែបង្កើតសាលាក្តីដល់ទៅបួន។ ការណ៍គឺវាមិនស្របគ្នាទៅនឹងគោលបំណងរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលតាមរយៈការអានសាមញ្ញនូវលក្ខន្តិកៈ និង របាយការណ៍របស់អគ្គលេខាធិការ គឺចង់ឲ្យបង្កើតសាលាក្តីមួយដែលមានអង្គជំនុំជម្រះបី និង អង្គជំនុំជម្រះសាលាឧទ្ធរណ៍មួយ អនុវត្តអង្គច្បាប់តែមួយ រួមគ្នា ស្របគ្នា និង មានហេតុផលត្រឹមត្រូវ។ តម្រូវការនៃភាពស្របគ្នា មានសារសំខាន់ជាពិសេសនៅក្នុងបរិបទដែលក្នុងនោះសាលាក្តីប្រព្រឹត្តទៅក្នុងពេលដែលបទដ្ឋានច្បាប់មនុស្សធម៌អន្តរជាតិ និង ច្បាប់ព្រហ្មទណ្ឌអន្តរជាតិកំពុងលូតលាស់ ហេតុដូច្នេះ បញ្ហានេះវារឹតតែសំខាន់ទៅទៀត ក្នុងពេលដែលជនទាំងឡាយដែលនៅចំពោះមុខសាលាក្តីគឺជនជាប់ចោទ និង ព្រះរាជអាជ្ញា ត្រូវដឹងឲ្យបានច្បាស់លាស់ថាតើរឿងក្តីទាំងនេះត្រូវជំនុំជម្រះដោយអនុវត្តតាមគោលការណ៍ច្បាប់អ្វី”។

“ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នានៅចំពោះមុខច្បាប់...”[47]។ សិទ្ធិនេះក៏មានចែងផងដែរនៅក្នុងសេចក្តីប្រកាសសាកលស្តីពីសិទ្ធិមនុស្ស[48] និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ[49] ដែល អ.វ.ត.ក ត្រូវគោរពតាម ដោយអនុលោមតាមរដ្ឋធម្មនុញ្ញកម្ពុជា[50] កិច្ចព្រមព្រៀង[51] និង ច្បាប់ស្តីពីការបង្កើត អ.វ.ក.ត[52]។ សិទ្ធិនេះក៏មានចែងផងដែរនៅក្នុងលក្ខន្តិកៈនៃសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ

---

[47] សិទ្ធិនេះមានចែងបន្ថែមទៀតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក្នុងមាត្រា ៣ ដែលចែងថា “បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពផ្សេងទៀតឡើយ”។

[48] មាត្រា ៧ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមុស្សចែងថា៖ “ជនគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ និង ត្រូវទទួលបានការការពារផ្នែកច្បាប់ឥតមានការរើសអើងអ្វីទាំងអស់។ ជនគ្រប់រូបមានសិទ្ធិទទួលបានការការពារស្មើគ្នា ប្រឆាំងនឹងការរើសអើងណាមួយ ដែលផ្ទុយទៅនឹងសេចក្តីប្រកាសនេះ និង ប្រឆាំងទៅនឹងការញុះញង់ឲ្យមានការរើសអើងដូច្នេះណាមួយ”។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស សេចក្តីសម្រេចរបស់មហាសន្និបាតលេខ 217A (III), U.N. Doc A/810 at 71 (១៩៤៨)។

[49] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ត្រូវបានអនុម័ត និង បើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក ដោយសេចក្តីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាតិលេខ 2200A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៧៦ អនុលោមតាមមាត្រា ៤៩ មាត្រា ១៤(១), ២៦។ មាត្រា ១៤(១) ចែងមួយផ្នែកថា “ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និង សាលាជម្រះក្តី”។ មាត្រា ២៦ ចែងមួយផ្នែកថា “ជនគ្រប់រូបមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ និង មានសិទ្ធិការពារពីច្បាប់ស្មើគ្នា ដោយឥតរើសអើង”។

[50] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ កែសម្រួលដោយក្រម ចុះថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៩៩៩ ប្រកាសឲ្យប្រើប្រាស់វិសោធនកម្មលើមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាដទៃទៀតពីជំពូក ៨ ដល់ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ០៤ ខែមិនា ឆ្នាំ ១៩៩៩ មាត្រា ៣១។

[51] មាត្រា ១២(២) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”) ចែងថា៖ “អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរសមស្របនៃច្បាប់ដូចដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលកម្ពុជាជាភាគីហត្ថលេខីមួយដែរ”។ មាត្រា ១៣(១) ចែងថា៖ “សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី”។

[52] មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“ច្បាប់ អ.វ.ត.ក”) ចែងថា៖ “អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនសមស្រប តាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ”។

សម្រាប់អតីតប្រទេស យូហ្គោស្លាវី[53] និង មានចែងនៅក្នុងលិខិតុបករណ៍សំខាន់ៗប្រចាំតំបន់មួយចំនួនទៀត[54] និង រដ្ឋធម្មនុញ្ញនៃរដ្ឋជាច្រើន[55]។ សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា នៅចំពោះមុខ អ.វ.ត.ក នឹងត្រូវរងការរំលោភបំពាន ដោយការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ប្រឆាំងនឹងរូបគាត់។

២២. កាតព្វកិច្ចគោរពសិទ្ធិ ដូចដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយសេចក្តីសម្រេចមួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ ២០០៧ ដែលនៅក្នុងនោះក្រុមប្រឹក្សាធម្មនុញ្ញបានបង្គាប់ថា៖

> ចៅក្រមម្នាក់មិនត្រូវពឹងផ្អែកតែទៅលើ [ច្បាប់ជាក់លាក់] ប៉ុណ្ណោះទេ ថែមទាំងត្រូវផ្អែកផងដែរលើច្បាប់ជាទូទៅ។ ពាក្យថាច្បាប់ខាងលើនេះ សំដៅលើច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល និង ច្បាប់ជាធរមានដទៃទៀត ព្រមទាំងអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់...[56]។

២៣. ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចនេះ ដោយគូសបញ្ជាក់ថា៖

> សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ... បញ្ជាក់យ៉ាងម៉ឺងម៉ាត់នូវឋានៈរបស់សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ថាជាផ្នែកមួយនៃច្បាប់កម្ពុជា ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និង លើកឡើងនូវចំណុចសំខាន់មួយថា ចៅក្រមជំនុំជម្រះ គួរតែយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្សជាមូលដ្ឋាន នៅពេលពិចារណាលើរឿងក្តីនានា[57]។

---

[53] លក្ខន្តិកៈនៃតុលាការ ICTY មាត្រា ២១(១)។

[54] *សូមមើល* ពិធីសារលេខ ១២ នៃអនុសញ្ញាអឺរ៉ុបសម្រាប់ការការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន។ អនុសញ្ញាអន្តរអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ២៤។

[55] *សូមមើល ឧទាហរណ៍* រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក វិសោធនកម្មលើកទី ១៤, រដ្ឋធម្មនុញ្ញបារាំង អនុម័តឆ្នាំ ១៩៥៨ មាត្រា ១, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសហព័ន្ធស្វ៊ីស មាត្រា ៧, ច្បាប់ស្តីពីសិទ្ធិរបស់ប្រទេស ណូវែលសេឡង់ ឆ្នាំ ១៩៩០ ផ្នែកទី ២ កថាខណ្ឌ ២៧, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប៉ូឡូញ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៧ មាត្រា ៣២, រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាធិបតេយ្យសង្គមនិយមស្រីលង្កា មាត្រា ១២, សេចក្តីព្រាងរដ្ឋធម្មនុញ្ញលើកទី ១ នៃសាធារណរដ្ឋសំប៊ី ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១២ មាត្រា ៤៥។

[56] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ 092/003/2007, ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ (បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា)។

[57] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, សេចក្តីថ្លែងការណ៍សាធារណៈ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញពាក់ព័ន្ធនឹងច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និង អនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៧។

២៤. សិទ្ធិទទួលបានការប្រព្រឹត្តិស្មើភាពគ្នានៅចំពោះមុខច្បាប់ តម្រូវឱ្យរឿងក្តីដែលមានលក្ខណៈស្មើគ្នាជាសត្យានុម័ត ទទួលបានការយកចិត្តទុកដាក់ស្មើភាពគ្នា។ គណៈកម្មាធិការសិទ្ធិមនុស្ស ជាអង្គការនៃអ្នកជំនាញឯករាជ្យ ដែលត្រួតពិនិត្យការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដោយរដ្ឋភាគី (ដូចជាប្រទេសកម្ពុជា)[58] បានគូសបញ្ជាក់ថា "សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និង សាលាជម្រះក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីមួយដោយយុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់នៃការការពារសិទ្ធិមនុស្ស និង បំពេញមុខងារជាមធ្យោបាយមួយនៃនីតិវិធីតុលាការក្នុងការធានាការពារនីតិរដ្ឋ"[59]។ គណៈកម្មាធិការសិទ្ធិមនុស្សបានគូសបញ្ជាក់បន្ថែមទៀតថា ប្រសិនបើមានការប្រព្រឹត្តិមិនស្មើភាពគ្នាណាមួយកើតឡើង ការប្រព្រឹត្តិនោះត្រូវតែ "ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលសមហេតុផល និង មានលក្ខណៈសត្យានុម័ត"[60]។

២៥. ករណីរបស់លោក មាស មុត មានលក្ខណៈស្មើគ្នាជាសត្យានុម័ត ដូចគ្នាទៅនឹងសំណុំរឿង ០០២ ទាក់ទងនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋរួមទម្រង់ទី ៣។ ពុំមានលក្ខណៈវិនិច្ឆ័យសមហេតុផល ឬដោយសត្យានុម័ត ដែលនឹងអនុញ្ញាតឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ប្រឆាំងនឹងលោក មាស មុត នោះឡើយ ដ្បិតតុលាការបានរកឃើញហើយថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ នេះមិនអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក ឡើយ ដោយផ្អែកលើច្បាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២។

---

[58] *សូមមើល* ការិយាល័យនៃឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, គណៈកម្មាធិការសិទ្ធិមនុស្ស, *អាចរកបាននៅលើ* គេហទំព័រ http://www2.ohchr.org/english/bodies/hrc/. ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៨០ និង បានចូលជាសមាជិកនៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៩២។ *សូមមើល* កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ *អាចរកបាននៅលើ* គេហទំព័រ http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-4&chapter=4&lang=en#3.

[59] គណៈកម្មាធិការសិទ្ធិមនុស្ស មតិទូទៅលេខ ៣២៖ មាត្រា ១៤៖ សិទ្ធិស្មើគ្នានៅចំពោះតុលាការ និង សាលាជម្រះក្តី និង សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០៧, អង្គការសហប្រជាជាតិ ឯកសារ CCPR/C/GC/32, *អាចរកបាននៅ* http://www1.umn.edu/humanrts/gencomm/hrcom32.html.

[60] *Rita Hiro Balani តទល់នឹង ប្រទេសអេស្ប៉ាញ*, ឯកសារទំនាក់ទំនងលេខ ១០២១/២០០១, អង្គការសហប្រជាជាតិ ឯកសារលេខ CCPR/C/77/D/1021/2001 (១៩៩៨), កថាខណ្ឌ ៤.៣ *អាចរកបាននៅ* http://www1.umn.edu/humanrts/undocs/1021-2001.html. *សូមមើលផងដែរ Waldman តទល់នឹង ប្រទេសកាណាដា* (ទស្សនៈដែលឯកភាពនៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៩) នៅក្នុងអង្គការសហប្រជាជាតិ ឯកសារលេខ GAOR, A/55/40 (vol. II), កថាខណ្ឌ ១០.០៦ *អាចរកបាននៅ* http://www.worldcourts.com/hrc/eng/decisions/1999.11.03_Waldman_v_Canada.htm.

២៦. សិទ្ធិទទួលបានការជំនុំជម្រះក្តីមួយដោយយុត្តិធម៌របស់លោក មាស មុត ដោយសាលាក្តីដែលឯករាជ្យ និង មិនលម្អៀង[61] គាំទ្រសេចក្តីសន្និដ្ឋានដែលថា គេមិនអាចប្រព្រឹត្តមកលើលោក មាស មុត ឲ្យខុសគ្នាពីជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ នោះឡើយ។ សិទ្ធិនេះមិនមែនទាមទារត្រឹមតែភាពយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ ថែមទាំងត្រូវធ្វើយ៉ាងណាឲ្យអ្នកសង្កេតការណ៍ឯករាជ្យដែលមានចំណេះដឹងនូវគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ ដឹងថាកិច្ចដំណើរការនីតិវិធីពិតជាមានភាពយុត្តិធម៌ដូច្នេះមែន[62]។ គ្មានអ្នកសង្កេតការណ៍ឯករាជ្យណាម្នាក់ នឹងយល់អំពីមូលហេតុដែលសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ គួរតែត្រូវបានអនុវត្ត មកលើលោក មាស មុត តែម្នាក់ឯងនោះទេ ជាពិសេសនៅពេលដែលតុលាការបានរកឃើញរួចទៅហើយក្នុងសំណុំរឿង ០០២ ថាទម្រង់នេះមិនអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក។

## III. ដំណោះស្រាយដែលស្នើសុំ

**អាស្រ័យ**ដូចបានបញ្ជាក់ជូនក្នុងសម្អាងហេតុទាំងអស់ខាងលើ មេធាវីការពារក្តីស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យ **បដិសេធ** ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី ៣ ប្រឆាំងនឹងលោក មាស មុត។

សូមទទួលដោយសេចក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០១៣
សហមេធាវីរបស់លោក មាស មុត

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

[61] *សូមមើល* មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ១២(២), ១៣(១) នៃកិច្ចព្រមព្រៀង មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ។

[62] *ព្រះរាជអាជ្ញា តទល់នឹង Furundžija*, IT-95-17/1-A, សាលក្រម ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០០ កថាខណ្ឌ ១៩០។